ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩ អនក្រ.បក

ក្រសួងសុខាភិបាល
ថ្ងៃទី ១៧ ខែ ០២ ឆ្នាំ ២០១៤ ម៉ោង ..... នាទី
ចុះបញ្ជីលេខ ០២៧៤

# អនុក្រឹត្យ
## ស្ដីពី
## ក្រមសីលធម៌គិលានុបដ្ឋាក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្ដីពីបែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ ភាពសុចរិត ប្រសិទ្ធភាព វិន័យការងារ ក្នុងការប្រកបវិជ្ជាជីវៈរបស់គិលានុបដ្ឋាក និងជាពិសេសទទួលបានទំនុកចិត្តពីសាធារណជន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈគិលានុបដ្ឋាកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគិលានុបដ្ឋាកទាំងអស់ ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈគិលានុបដ្ឋាកពីក្រសួងសុខាភិបាល។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**គិលានុបដ្ឋាក** សំដៅដល់នីតិជនដែលមានសញ្ញាបត្រគិលានុបដ្ឋាកចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាបត្រចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

**វិជ្ជាជីវៈគិលានុបដ្ឋាក** សំដៅដល់ការផ្តល់នូវសេវាថែទាំសុខភាពចំពោះបុគ្គលគ្រប់វ័យ ក្រុមគ្រួសារ និងផ្តល់សេវានៅតាមសហគមន៍ និងគ្រឹះស្ថានថែទាំសុខភាព។ ការថែទាំរាប់បញ្ចូលទាំងការលើកកម្ពស់សុខភាព ការបង្ការជំងឺ ការថែទាំអ្នកជំងឺ ការថែទាំជនពិការ និងអ្នកជំងឺមុននិងក្រោយស្លាប់។

**គ្រឹះស្ថានថែទាំ** សំដៅដល់កន្លែងដែលគិលានុបដ្ឋាកបម្រើការងារ ដូចជាមន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក បន្ទប់ថែទាំឯកជនជាដើម ដែលមានការទទួលស្គាល់ឬការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី២

## ករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់គិលានុបដ្ឋាក

**មាត្រា៥ .-**

ដើម្បីសម្រេចករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួន គិលានុបដ្ឋាក៖

១- ត្រូវប្រកបវិជ្ជាជីវៈដោយមានមេត្តាធម៌ចំពោះអ្នកជំងឺ ដោយមានគុណធម៌ អាកប្បកិរិយាល្អ សម្តីសុភាពរាបសា ត្រឹមត្រូវ និងយកចិត្តទុកដាក់។

២- ត្រូវគោរពជីវិត រាងកាយ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺនៅពេលផ្តល់សេវា

៣- ត្រូវថែទាំប្រកបដោយមានលក្ខណៈមិនលម្អៀង មិនរើសអើង ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់អ្នកជំងឺ ជនជាតិ ជាតិសាសន៍ ភេទ ភាសា សាសនា វប្បធម៌ និន្នាការនយោបាយ ឬស្ថានភាពជំងឺនោះទេ។

៤- ត្រូវមានគណនេយ្យភាពក្នុងការវិនិច្ឆ័យនិងការអនុវត្តការងារ នៅពេលផ្តល់ការថែទាំដល់អ្នកជំងឺ។

៥- ត្រូវមានគណនេយ្យភាពក្នុងការផ្ទេរកិច្ចការឱ្យគិលានុបដ្ឋាកឬបុគ្គលិកសុខាភិបាលផ្សេងទៀត ដើម្បីឱ្យការផ្ទេរកិច្ចការមានសុវត្ថិភាពដល់អ្នកជំងឺ។

៦- ត្រូវបំពេញការងារដោយគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន គោលការណ៍ណែនាំជាតិ និងពិធីសារជាតិដែលទាក់ទងនឹងវិជ្ជាជីវៈគិលានុបដ្ឋាក។

៧- ត្រូវប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនចំពោះឥស្សរភាពវិជ្ជាជីវៈគិលានុបដ្ឋាក នៅគ្រប់កាលៈទេសៈទាំងអស់។

៨- ត្រូវចូលរួមអនុវត្តគោលនយោបាយយុទ្ធសាស្ត្រជាតិឱ្យមានប្រសិទ្ធភាព និងសហការគ្នាក្នុងការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សុខភាពអតិថិជន។

៩- ត្រូវផ្តល់សេវាថែទាំសុខភាពប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ហើយនៅក្នុងករណីចាំបាច់ ត្រូវមានការសហការជាមួយក្រុមបុគ្គលិកសុខាភិបាលនិងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធានាថាគ្រោះថ្នាក់ដល់អ្នកជំងឺត្រូវបានកាត់បន្ថយ។

១០- ត្រូវអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំដោយចូលរួមក្នុងការដឹកនាំ បណ្តុះបណ្តាលបន្តការស្រាវជ្រាវដើម្បីទទួលព័ត៌មានបន្ថែមថ្មីៗ។

១១- ត្រូវអភិវឌ្ឍវិជ្ជាជីវៈគិលានុបដ្ឋាកតាមរយៈការចូលរួមរៀបចំនិងកែលម្អពិធីសារជាតិ គោលការណ៍ណែនាំជាតិ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

១២- ត្រូវគោរពការសម្ងាត់វិជ្ជាជីវៈនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានាទៅនឹងស្ថានភាព សុខភាព រោគវិនិច្ឆ័យ ការវិវត្ត និងព័ត៌មានផ្ទាល់ខ្លួនដើម្បីរក្សាភាពជាឯកជន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺ។

១៣- ត្រូវគោរពសិទ្ធិរបស់អ្នកជំងឺក្នុងការជ្រើសរើសគិលានុបដ្ឋាកនិងត្រូវជួយសម្របសម្រួលដល់អ្នកជំងឺក្នុងការជ្រើសរើសគិលានុបដ្ឋាកដោយឆន្ទៈរបស់សាមីខ្លួន។

១៤- គោរពសិទ្ធិទទួលយក សិទ្ធិបដិសេធ ឬសិទ្ធិសុំបញ្ឈប់ការថែទាំរបស់អ្នកជំងឺគ្រប់ពេល។

១៥- ត្រូវចូលរួមផ្តល់មតិដើម្បីការពារសិទ្ធិរបស់អ្នកជំងឺ គ្រួសារ និងសហគមន៍ដែលមានទំនាក់-ទំនងជាមួយនឹងការថែទាំសុខភាពអ្នកជំងឺ លើកកម្ពស់សុខភាព ការស្តារនីតិសម្បទានិងការបង្ការជំងឺ។

១៦- ត្រូវការពារនិងថែរក្សាសុខភាពផ្ទាល់ខ្លួនដើម្បីអនុវត្តការងារឱ្យបានល្អ ដោយមិនផ្តល់ផលប៉ះពាល់អវិជ្ជមានដល់អ្នកជំងឺ។

**មាត្រា៦ ._**

គិលានុបដ្ឋាកត្រូវផ្តល់ឱសថតាមវេជ្ជបញ្ជាឬតាមគោលការណ៍ណែនាំថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល។

**មាត្រា៧ ._**

គិលានុបដ្ឋាកត្រូវស្ថិតនៅជាមួយអ្នកជំងឺជានិច្ច។ ក្នុងករណីអ្នកជំងឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ គិលានុបដ្ឋាកត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ឬត្រូវធ្វើការសង្គ្រោះបឋមនិងបញ្ជូនទៅសេវាថែទាំសុខភាព ឬសេវាសមស្របផ្សេងទៀតតាមការចាំបាច់។

**មាត្រា៨ ._**

ដើម្បីអនុវត្តករណីយកិច្ចនិងការទទួលខុសត្រូវទូទៅរបស់ខ្លួនឱ្យបានល្អ គិលានុបដ្ឋាកៈ

១- មិនត្រូវធ្វើការងារណាដែលនាំឱ្យប៉ះពាល់ អាប់ឱនកិត្តិយស និងសេចក្តីថ្លៃថ្នូរដល់វិជ្ជាជីវៈគិលានុបដ្ឋាកឡើយ។

២- មិនត្រូវប្រើឥទ្ធិពលរបស់ខ្លួនដើម្បីទទួលបាននូវកិច្ចសន្យា បុព្វសិទ្ធិ សិទ្ធិ ឬផលប្រយោជន៍ពីអ្នកជំងឺ។

៣- មិនត្រូវប្រព្រឹត្តនូវអំពើទាំងឡាយដើម្បីប្រាក់កម្រៃជើងសា។

៤- មិនត្រូវបំពេញការងារថែទាំនៅទីសាធារណៈ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

៥- មិនត្រូវចេញវិញ្ញាបនបត្រនិងលិខិតបញ្ជាក់ផ្សេងៗដែលទាក់ទងនឹងវិជ្ជាជីវៈគិលានុបដ្ឋាក។

៦- មិនត្រូវទារថ្លៃសេវាលើសតម្លៃកំណត់ឬផ្តល់ព័ត៌មានក្លែងក្លាយទាក់ទងនឹងកម្រៃសេវារបស់ខ្លួន។

៧- មិនត្រូវប្រើរហស្សនាមក្នុងការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក។

៨- មិនត្រូវផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មអំពីសេវាថែទាំរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីគណៈគិលានុបដ្ឋាករាជធានី ខេត្តឡើយ។

៩- មិនត្រូវបង្ហាញអត្តសញ្ញាណរបស់អ្នកជំងឺតាមរយៈការផ្សព្វផ្សាយជាសាធារណៈឬក្នុងគោលបំណងវេជ្ជសាស្ត្រឡើយ លើកលែងតែមានការយល់ព្រមពីអ្នកជំងឺដែលជាសាមីខ្លួន។

១០- មិនត្រូវផ្តល់សេវាឬប្រឹក្សាយោបល់វិជ្ជាជីវៈគិលានុបដ្ឋាកដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវសង្គ្រោះបន្ទាន់។

១១- មិនត្រូវប្រព្រឹត្តអំពើទុច្ចរិត ដូចជាការឆបោកអ្នកជំងឺ ជំរិតទារប្រាក់ឬវត្ថុមានតម្លៃពីអ្នកជំងឺ ឬក្លែងបន្លំព័ត៌មានរបស់អ្នកជំងឺ។

**មាត្រា៩ ._**

គិលានុបដ្ឋាកដែលមានតួនាទីក្នុងអាណត្តិជាប់ឆ្នោតឬតំណែងផ្លូវការណាមួយ មិនត្រូវប្រើតួនាទីនោះដើម្បីទាក់ទាញអតិថិជនឡើយ។

## ជំពូកទី៣
## ទំនាក់ទំនងរវាងគិលានុបដ្ឋាកនិងអតិថិជន

**មាត្រា១០ .-**

ក្នុងករណីដែលអ្នកជំងឺ គ្រួសារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ បដិសេធការថែទាំសុខភាព គិលានុបដ្ឋាកត្រូវគោរពតាមការសម្រេចចិត្តរបស់អ្នកទាំងនោះ តែត្រូវពន្យល់អំពីផលវិបាកនានាដែលអាចកើតមានឡើង។

**មាត្រា១១ .-**

គិលានុបដ្ឋាកត្រូវជូនដំណឹងអំពីស្ថានភាពសុខភាពរបស់អ្នកជំងឺឬការវិវត្តនៃជំងឺដល់អ្នកជំងឺ។ ការជូនដំណឹងដល់ក្រុមគ្រួសារឬតំណាងស្របច្បាប់ ត្រូវមានការយល់ព្រមពីសាមីខ្លួន។

**មាត្រា១២ .-**

គិលានុបដ្ឋាកអាចបដិសេធមិនផ្តល់សេវាថែទាំដល់អ្នកជំងឺណាម្នាក់ ដោយមានហេតុផលវិជ្ជាជីវៈឬហេតុផលផ្ទាល់ខ្លួនបាន លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។ ប្រសិនបើសេវាថែទាំត្រូវបានបដិសេធបែបនេះ គិលានុបដ្ឋាកត្រូវបញ្ជូនអ្នកជំងឺទៅកាន់សេវាផ្សេងទៀតដែលមានសុវត្ថិភាព។

**មាត្រា១៣ .-**

គិលានុបដ្ឋាកដែលត្រូវពិនិត្យអនីតិជនឬអសមត្ថជនដែលមានអាយុ១៨ឆ្នាំឡើងទៅ ត្រូវជូនដំណឹងដល់ឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់របស់ជននោះ ហើយគិលានុបដ្ឋាកត្រូវស្វែងរកការយល់ព្រមពីអ្នកទាំងនោះ នៅមុនពេលចាប់ផ្តើមផ្តល់សេវា។

ក្នុងករណីបន្ទាន់ដែលអាចគ្រោះថ្នាក់ដល់ជីវិត ទោះបីជាមិនអាចធ្វើការទាក់ទងនឹងអ្នកទាំងនោះបានក៏ដោយ ក៏គិលានុបដ្ឋាកត្រូវតែផ្តល់សេវាជាចាំបាច់ ដោយមានវត្តមាននិងការឯកភាពពីអ្នករួមការងារ។ ប្រសិនណាសាមីជនអាចបញ្ចេញមតិបាន គិលានុបដ្ឋាកត្រូវពិចារណាដល់មតិនេះ បើអាចធ្វើទៅបាន។

**មាត្រា១៤ .-**

គិលានុបដ្ឋាកត្រូវផ្តល់ការការពារពិសេសចំពោះអនីតិជនឬអសមត្ថជនដែលមានអាយុ១៨ឆ្នាំឡើងទៅ ប្រសិនបើអ្នកទាំងនោះមិនបានទទួលការថែទាំឬផលប្រយោជន៍និងសិទ្ធិខាងសុខភាព បានត្រឹមត្រូវ។ ក្នុងករណីបែបនេះ គិលានុបដ្ឋាកត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

**មាត្រា១៥ .-**

គិលានុបដ្ឋាកឬគ្រឹះស្ថានថែទាំត្រូវបង្ហាញតម្លៃសេវាទៅលើការពិគ្រោះយោបល់ និងសេវាថែទាំដទៃទៀតមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

**មាត្រា១៦ ._**

ក្នុងករណីដែលមានគ្រោះថ្នាក់ក្នុងទីសាធារណៈ គិលានុបដ្ឋាកមិនត្រូវបោះបង់អ្នកជំងឺនោះទេ លើកលែងតែមានបទបញ្ជាណាមួយពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌច្បាប់។

**មាត្រា១៧ ._**

គិលានុបដ្ឋាកមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការគ្រួសារឬក្នុងជីវភាពផ្ទាល់ខ្លួនរបស់អ្នកជំងឺឡើយ បើពុំមានមូលហេតុវិជ្ជាជីវៈ។

## ជំពូកទី៤
## ទំនាក់ទំនងរវាងគិលានុបដ្ឋាកនិងសហភាគរៈ
## រវាងគិលានុបដ្ឋាកនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត

**មាត្រា១៨ ._**

គិលានុបដ្ឋាកត្រូវពង្រឹងទំនាក់ទំនងល្អជាមួយសហភាគរៈនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត តាមរយៈការជំរុញការគាំទ្រគ្នាទៅវិញទៅមកដើម្បីជាផលប្រយោជន៍ដល់ការថែទាំសុខភាពសាធារណៈ សុខុមាលភាពសហគមន៍និងកន្លែងធ្វើការ។

គិលានុបដ្ឋាកត្រូវប្រព្រឹត្តដោយការគោរពចំពោះគិលានុបដ្ឋាកផ្សេងទៀត និស្សិត សហការី និងបុគ្គលិកសុខាភិបាល។ ការគោរពសហការី រួមមានការទទួលស្គាល់ ការទទួលយកនូវចំណេះដឹង បទពិសោធ និងជំនាញរបស់ពួកគេ។

**មាត្រា១៩ ._**

គិលានុបដ្ឋាកត្រូវអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយសហការជាមួយឬស្វែងរកដំបូន្មានឬសុំជំនួយពីគិលានុបដ្ឋាកដទៃឬពីគ្រូពេទ្យជំនាញតាមស្ថានភាពសមស្រប លើកលែងតែក្នុងករណីដែលការងារនោះផ្ទុយនឹងវិជ្ជាជីវៈគិលានុបដ្ឋាក។

**មាត្រា២០ ._**

នៅពេលបានទទួលការប្រគល់ដើម្បីផ្តល់សេវាថែទាំចំពោះអ្នកជំងឺដែលសហភាគរៈម្នាក់ទៀតបានផ្តល់សេវារួចហើយ៖

- គិលានុបដ្ឋាកជំនួសត្រូវបានទទួលការយល់ព្រមជាមុនពីអ្នកជំងឺ
- គិលានុបដ្ឋាកជំនួសត្រូវទាក់ទងជាមួយគិលានុបដ្ឋាកមុន ដើម្បីស្វែងរកយោបល់ឬដំបូន្មានមុននឹងបន្តផ្តល់សេវាថែទាំ
- នៅពេលបញ្ចប់ការជំនួស គិលានុបដ្ឋាកជំនួសត្រូវបញ្ឈប់សកម្មភាពទាក់ទងនឹងការជំនួសទាំងអស់និងប្រគល់ព័ត៌មានចាំបាច់ផ្សេងៗដល់គិលានុបដ្ឋាកមុនដើម្បីនិរន្តរភាពនៃការថែទាំ។

**មាត្រា២១ .-**

គិលានុបដ្ឋាកត្រូវគ្រប់គ្រងនិងទទួលខុសត្រូវលើនិស្សិតអន្តេវាសិកគិលានុបដ្ឋាកដែលកំពុងបំពេញការងារក្នុងកន្លែងធ្វើការរបស់ខ្លួន។

**មាត្រា២២ .-**

គិលានុបដ្ឋាកមិនត្រូវបង្កើតក្រុមឬបណ្តាញក្នុងគោលបំណងដើម្បីរើសអើងសហភាគរៈឡើយ។

**មាត្រា២៣ .-**

គិលានុបដ្ឋាកមិនត្រូវធ្វើអ្វីដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់គិលានុបដ្ឋាកណាម្នាក់ឡើយ។

## ជំពូកទី៥
## ការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក

**មាត្រា២៤ .-**

គិលានុបដ្ឋាកអាចបោះពុម្ពអត្តសញ្ញាណផ្ទាល់ខ្លួននិងព័ត៌មានមួយចំនួនដោយសុចរិត ទៀងត្រង់ដូចខាងក្រោមនេះ៖

១- នាមត្រកូលនិងនាមខ្លួន គុណវុឌ្ឍិ លេខចុះបញ្ជីក្នុងគណៈគិលានុបដ្ឋាកកម្ពុជា អាសយដ្ឋានប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ ថ្ងៃ និងពេលវេលាសម្រាប់ផ្តល់សេវាថែទាំ។

២- នាមត្រកូលនិងនាមខ្លួនគិលានុបដ្ឋាកទាំងអស់ក្នុងក្រុម ប្រសិនបើគិលានុបដ្ឋាកប្រកបមុខរបរជាក្រុម។

**មាត្រា២៥ .-**

ការបញ្ជាក់មួយចំនួនដែលគិលានុបដ្ឋាកឬគ្រឹះស្ថានថែទាំ ត្រូវបានអនុញ្ញាតឱ្យសរសេរនៅលើផ្លាកកន្លែងធ្វើការមាន៖

១- នាមត្រកូលនិងនាមខ្លួន លេខចុះបញ្ជីក្នុងគណៈគិលានុបដ្ឋាកកម្ពុជា អាសយដ្ឋាន ប្រកបវិជ្ជាជីវៈ លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានអ៊ីមែល គេហទំព័រ។

២- នាមត្រកូលនិងនាមខ្លួនលេខចុះបញ្ជីក្នុងគណៈគិលានុបដ្ឋាកកម្ពុជានៃគិលានុបដ្ឋាកទាំងអស់ដែលប្រកបវិជ្ជាជីវៈនៅក្នុងគ្រឹះស្ថានថែទាំនោះ។

៣- តារាងកំណត់តម្លៃសេវាថែទាំសុខភាព។

**មាត្រា២៦ .-**

គិលានុបដ្ឋាកត្រូវបានអនុញ្ញាតឱ្យធ្វើការនៅស្ថាប័នឯកជន ក្នុងនាមជាគិលានុបដ្ឋាកឯកជន។ ប្រសិនបើគិលានុបដ្ឋាកធ្វើការនៅស្ថាប័នរដ្ឋនិងឯកជន ការងារឯកជនមិនត្រូវប៉ះពាល់ដល់ការងាររដ្ឋរបស់ខ្លួនឡើយ។

**មាត្រា២៧ .-**

គិលានុបដ្ឋាកដែលផ្តល់សេវា ហើយកំពុងមានបញ្ហាជាមួយអ្នកជំងឺទទួលសេវា មិនអាចជាសមាជិកគណៈកម្មការវិន័យក្នុងករណីនេះឡើយ។

គិលានុបដ្ឋាកដែលធ្វើការនៅគ្រឹះស្ថានថែទាំជាមួយគ្នា ឬជាញាតិលោហិតផ្ទាល់ ឬសហព័ទ្ធ ឬជាញាតិពន្ធ ក្នុង៣ថ្នាក់របស់គិលានុបដ្ឋាក ឬមានទំនាក់ទំនងជាមួយនឹងគិលានុបដ្ឋាកដែលកំពុងជាប់ពាក់ព័ន្ធក្នុងសកម្មភាពដាក់វិន័យ មិនអាចជាសមាជិកគណៈកម្មការវិន័យឡើយ។

**មាត្រា២៨ .-**

គិលានុបដ្ឋាកដែលជាសមាជិកគណៈកម្មការវិន័យ ត្រូវឯករាជ្យនៅក្នុងមុខងារ។

គិលានុបដ្ឋាកមិនត្រូវលម្អៀងក្នុងការបង្ហាញហេតុផលឬធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធ ចំពោះករណីដែលខ្លួនត្រូវត្រួតពិនិត្យនោះទេ។

**មាត្រា២៩ .-**

គិលានុបដ្ឋាកត្រួតពិនិត្យមិនត្រូវជ្រៀតជ្រែកឬកែប្រែការថែទាំឡើយ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះកំណត់ដោយច្បាប់។

**មាត្រា៣០ .-**

គិលានុបដ្ឋាកត្រួតពិនិត្យត្រូវគោរពការសម្ងាត់វិជ្ជាជីវៈតាមបទប្បញ្ញត្តិជាធរមាន។ របាយការណ៍ ឬឯកសារដែលមានសម្គាល់អត្តសញ្ញាណរបស់អ្នកជំងឺទទួលសេវា ឬរបស់គិលានុបដ្ឋាកពិនិត្យថែទាំ មិនត្រូវបង្ហាញដល់ស្ថាប័នដែលមិនពាក់ព័ន្ធឬសាធារណជនឡើយ។

## ជំពូកទី៦
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា៣១ .-**

គិលានុបដ្ឋាកទាំងអស់ នៅពេលសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈគិលានុបដ្ឋាក ត្រូវបញ្ជាក់នៅចំពោះមុខក្រុមប្រឹក្សាគណៈគិលានុបដ្ឋាករាជធានី ខេត្ត ថាខ្លួនបានយល់ដឹងច្បាស់លាស់ពីអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាកនេះរួចហើយ និងសន្យាជាលាយលក្ខណ៍អក្សរថាគោរពតាមក្រមសីលធម៌នេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**មាត្រា៣២ .-**

គិលានុបដ្ឋាកដែលផ្តល់សេចក្តីបញ្ជាក់មិនត្រឹមត្រូវឬមិនពេញលេញដោយចេតនា ធ្វើឡើងជូនក្រុមប្រឹក្សាគណៈគិលានុបដ្ឋាករាជធានី ខេត្ត អាចនាំឱ្យមានការចោទប្រកាន់ខាងវិន័យ។

**មាត្រា៣៣ .-**

គិលានុបដ្ឋាកដែលឈប់ប្រកបមុខរបរឬកែប្រែលក្ខខណ្ឌនៃការប្រកបមុខរបរ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈគិលានុបដ្ឋាករាជធានី ខេត្ត។ ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាករាជធានី ខេត្តដែលទទួលដឹងឮអំពីការឈប់ឬការកែប្រែនេះ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ។

**មាត្រា៣៤ ._**

សេចក្ដីសម្រេចទាំងឡាយរបស់គណៈគិលានុបដ្ឋាកគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តតាមអនុក្រឹត្យនេះ ត្រូវតែមានមូលហេតុច្បាស់លាស់។

**មាត្រា៣៥ ._**

ក្នុងករណីដែលមិនយល់ស្របនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាករាជធានី ខេត្ត អ្នកជំងឺទទួលសេវា ឬគិលានុបដ្ឋាកដែលផ្ដល់សេវាអាចមានរយៈពេល២ខែ ដើម្បីសុំឱ្យក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិពិនិត្យសេចក្ដីសម្រេចនោះឡើងវិញ។

**មាត្រា៣៦ ._**

ក្នុងករណីដែលមិនបានអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈដូចមានចែងក្នុងអនុក្រឹត្យនេះ គិលានុបដ្ឋាក ត្រូវទទួលទណ្ឌកម្មខាងវិន័យដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ជាពិសេសផ្អែកតាមមាត្រា២៨ នៃព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៣៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខៈ....០០៥.........ស.នក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជូនមក

គ្រប់អង្គភាពថ្នាក់កណ្ដាល ដើម្បីផ្សព្វផ្សាយនិងអនុវត្ត ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

វេជ្ជ. យក់_សម្បត្តិ